# វិធីសាស្ត្រគណនាបរិមាណឧស្ម័នកាបូនិច $Co_2$ ដែលស្រូបដោយ ដើមឈើមួយដើមក្នុងរយៈពេលមួយឆ្នាំ

*រៀបចំដោយ សុខ ហេង យោងតាមឯកសាររបស់ Trees for the Future*

កម្រិតនៃការស្រូបយកឧស្ម័នកាបូនិចរបស់ដើមឈើគឺអាស្រ័យលើល្បឿនលូតលាស់របស់ប្រភេទឈើ លក្ខខណ្ឌទីតាំង ដែលឈើនោះដុះ និង ដង់ស៊ីតេនៃសហគមន៍ព្រៃនោះ។ គេអាចគណនាការស្រូបឧស្ម័នកាបូនិចរបស់ដើមឈើមួយដើមក្នុងមួយឆ្នាំ តាមជំហានដូចខាងក្រោម :

១. គណនាទម្ងន់ឈើស្រស់សរុប
២. គណនាទម្ងន់ឈើស្ងួត
៣. គណនាទម្ងន់កាបូនក្នុងដើមឈើ
៤. គណនាទម្ងន់ឧស្ម័នកាបូនិចដែលស្រូបដោយដើមឈើសរុប
៥. គណនាទម្ងន់ឧស្ម័នដែលស្រូបដោយដើមឈើក្នុង ១ ឆ្នាំ

**១. របៀបគណនាទម្ងន់សរុបរបស់ដើមឈើ**

តាង W : ទម្ងន់ឈើស្រស់ (គិតជាផោន)
D : ប្រវែងអង្កត់ផ្ចិតដើមឈើ (គិតជាអ៊ីញ)
H : កម្ពស់ដើមឈើ (គិតជាហ្វីត)

ក្នុងករណី D < ១១ នោះ $W = 0.25 D^2H$
ក្នុងករណី D ≥ ១១ នោះ $W = 0.15 D^2H$

មេគុណ 0.15 ឬ 0.25 អាចប្រែប្រួលទៅតាមប្រភេទឈើ ប៉ុន្តែកម្រិតមេគុណនេះគឺជាកម្រិតមួយដែលអាចប្រើប្រាស់ ទូទៅសម្រាប់គណនាទម្ងន់ឈើគ្រប់ប្រភេទ ។





ជាមធ្យមប្រព័ន្ធឫសក្រោមដីរបស់ឈើមានទម្ងន់ស្មើនឹង ២០% នៃទម្ងន់ផ្នែកខាងលើដីរបស់ដើមឈើ។ ដូចនេះដើម្បីបានទម្ងន់ដើមឈើស្រស់សរុបគេត្រូវយកទម្ងន់ឈើផ្នែកខាងលើដី គុណនឹង ១២០% ។

**២. របៀបគណនាទម្ងន់ឈើស្ងួត**

យោងតាមការស្រាវជ្រាវរបស់មហាវិទ្យាល័យ Nebraska ជាមធ្យម ឈើមួយដើមមានទម្ងន់ឈើស្ងួត ចំនួន ៧២,៥ %និងសំណើម (ជាតិទឹក) ចំនួន ២៧,៥ % នៃទម្ងន់ដើមឈើស្រស់សរុប ។ ដូចនេះដើម្បីបានទម្ងន់ឈើស្ងួតសរុបត្រូវយកទម្ងន់ ដើមឈើស្រស់សរុប គុណនឹង ៧២,៥% ។

**៣. របៀបគណនាទម្ងន់កាបូនក្នុងដើមឈើ**

ជាមធ្យមទម្ងន់កាបូនស្មើនឹង៥០% នៃទម្ងន់ឈើស្ងួត ។ ដូចនេះដើម្បីបានទម្ងន់កាបូន គេត្រូវយកទម្ងន់ឈើស្ងួតគុណនឹង ៥០% ។

**៤. របៀបគណនាឧស្ម័នកាបូនិច (Carbon Dioxide) ដែលស្រូបដោយដើមឈើសរុប**

ឧស្ម័នកាបូនិច ($CO_2$) គឺផ្សំផ្គុំឡើងដោយម៉ូលេគុល

កាបូន (C) ចំនួនមួយ និង ម៉ូលេគុលអុកស៊ីហ្សែន (O) ចំនួនពីរ។

ទម្ងន់អាតូមរបស់កាបូនគឺ 12.001115

ទម្ងន់អាតូមអុកស៊ីហ្សែនគឺ 15.9994

ទម្ងន់របស់ $CO_2$ KW C + ( 2 x O ) = 43.999915

ដូចនេះផលធៀបរវាងកាបូន និងឧស្ម័ន ( Ratio of $CO_2$ to C ) គឺ 43.999915/12.001115 = 3.6663

ដើម្បីបានទម្ងន់ឧស្ម័នកាបូនិចស្រូបដោយដើមឈើ គឺត្រូវយកទម្ងន់កាបូនរបស់ដើមឈើនោះ គុណនឹង 3.6663 ។

## ៥. របៀបគណនាទម្ងន់ $CO_2$ ស្រូបដោយដើមឈើមួយដើមក្នុងមួយឆ្នាំ

យើងត្រូវយកទម្ងន់ $CO_2$ ស្រូបដោយដើមឈើចែកនឹង ចំនួនអាយុដើមឈើនោះ។

**ឧទាហរណ៍**

ដើមឈើមួយដើមដែលមានអាយុ ១០ ឆ្នាំមានកម្ពស់ ១៥ ហ្វីត និង អង្កត់ផ្ចិតប្រវែង ៨ អ៊ីញ :

ទម្ងន់ផ្នែកខាងលើដី W= 0.25 $D^2H$ = 0.25($8^2$)(15) = ២៤០ផោន (=108.7 kg )

ទម្ងន់សរុប = 240 x 120% = 288 epan (= 130.5kg )

ទម្ងន់ស្ងួត = 288 x 72.5 = 208.8 epan (= 94.6kg)

ទម្ងន់កាបូន = 208.8 x 50% = 104.4 epan ( = 47.3kg)

$CO_2$ដែលស្រូប =104.4 x 3.6663 = 382.8epan(=173.4kg)

$CO_2$ ដែលស្រូបក្នុង១ឆ្នាំ = 382.2 /10= 38.2epan(=17.3kg)

បើផ្អែកតាមការស្រាវជ្រាវរបស់លោក MYERS ELAK GOREAU និងបង្ហាញថាចំការឈើស្រល់ និងប្រេងខ្យល់ដាំនៅតំបន់ត្រូពិចមួយហិកតាអាចស្រូបជាមធ្យមបានកាបូន ១០តោន ក្នុងមួយឆ្នាំ ឬ 73,326 ផោនក្នុង១ដើម/ឆ្នាំ (ក្នុងករណី ដាំ ១០០០ ដើម/ហិកតា ) ។

**ចំណាំ**

តួលេខទាំងអស់ខាងលើជាតួលេខបានមកពីការសិក្សាស្រាវជ្រាវឈើនៅប្រទេសផ្សេងៗ ។ ដូចបានជំរាបខាងលើ តួលេខនេះ អាចប្រែប្រួលពីតំបន់មួយទៅតំបន់មួយទៀត។ ដូចនេះត្រូវមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ ជាពិសេស លក្ខណៈរូបសាស្ត្រ និង ល្បឿនលូតលាស់ឈើអាចមាន លក្ខណៈ និងកម្រិតខុសគ្នា។



ចំការឈើក្លូនប្រេងខ្យល់ K7 អាយុ២ឆ្នាំ







ចំការឈើដាំឡើងវិញ នៅខេត្តកំពង់ឆ្នាំង

# លទ្ធផលស្រាវជ្រាវពពួកថនិកសត្វធំៗក្នុងព្រៃការពារព្រះវិហារ ២០០៦_២០០៩

## Large Mammal Surveys in Preah Vihear Protected Forest, Cambodia

*ដោយ តាន់ សេដ្ឋា នាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ*

### សេចក្តីផ្តើម

ព្រៃការពារព្រះវិហារស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋបាលព្រៃឈើចាប់តាំងពីឆ្នាំ ២០០២ មក ក្រោមជំនួយថវិកា UNDP/GEF ដែលមានអង្គការ WCS ជាអ្នកអនុវត្តគម្រោងជាមួយរដ្ឋបាលព្រៃឈើទាំងថវិកានិងបច្ចេកទេសតាំងពីមុននៃការបង្កើតព្រៃការពារចាប់តាំងពីឆ្នាំ ១៩៩៩។ ដើម្បីធ្វើការគ្រប់គ្រង ព្រៃការពារឲ្យមានប្រសិទ្ធភាពយើងបានធ្វើការសិក្សាស្រាវជ្រាវ ប្រភេទថនិកសត្វធំៗ ដែលមាននៅក្នុង




*ផែនទី ទីតាំងព្រៃការពារព្រះវិហារ និងអតីតព្រៃសម្បទានចិន្តាធ្លាយវូត*

និង ជុំវិញព្រៃការពារ ចាប់តាំងពី ឆ្នាំ ២០០៦ រហូតដល់ ២០០៩ ។

### វិធីសាស្ត្រ និងទីតាំងសិក្សា

ការសិក្សាស្រាវជ្រាវ គឺយកទីតាំងព្រៃការពារ និងតំបន់ព្រៃសំខាន់ៗមួយចំនួនដែលនៅក្បែរទំហំព្រៃសិក្សាស្រាវជ្រាវ ១៩០១០៦ ហិកតា ដែលជាប្រភេទទីជម្រកព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង និងព្រៃស្រោងរួមទាំងតំបន់វាលស្មៅផងដែរ ។ ប្រភេទសត្វព្រៃដែលផ្តោតសំខាន់ក្នុងការសិក្សារួមមាន ខ្ទីង ទន្សោង ប្រើស ឈ្លូស ក្តាន់ញៀង និង ជ្រូកព្រៃ។ ដោយខ្ទៀកទន្សោង និង រមាំងជាប្រភេទជិតផុតពូជ ខ្ទីងនិងប្រើសជាប្រភេទមានដោយកម្រ ។ ក្នុងនោះ អំបូរ ពានរបីប្រភេទក៏ត្រូវបានកត់ត្រាផងដែរគឺស្វាព្រាម ស្វាក្តាម និងទោចម្កុដ រួមទាំងប្រភេទថនិកសត្វធំៗផ្សេងទៀត ក៏ត្រូវបានកត់ត្រាផងដែរដូចជា ដំរី និងមំសាសីសត្វជាដើម ។

ការសិក្សាស្រាវជ្រាវគឺធ្វើឡើងតាមបន្ទាត់ត្រង់សិកដែលបានកំណត់ចម្ងាយស្តង់ដាមួយ (Buckland *et al,* 2001) ដើម្បីស្វែងរកចំនួនប្រហែលមួយ រួមទាំងដង់ស៊ីតេផងដែរ។ ទិន្នន័យ ដែលប្រមូលបានគឺនៅរដូវប្រាំងដែលត្រង់សិកនីមួយៗត្រូវបានពិនិត្យអតិបរមាចំនួនប្រាំបីដង ចំនួនត្រង់សិកមានការកើនឡើង ក្នុងរយៈពេលបួនឆ្នាំ ដើម្បីឲ្យភាពលំអៀងដង់ស៊ីតេ នៃប្រភេទសត្វព្រៃកាន់តែតិច ។ ទីតាំងសត្វព្រៃរស់នៅ ចំនួនសត្វព្រៃ និង ចម្ងាយពីត្រង់សិកទៅសត្វព្រៃក៏ត្រូវបានធ្វើផងដែរ ។ ជាទូទៅយើងមិនអាចរាប់ចំនួនសត្វព្រៃក្នុងក្រុមប្រភេទនីមួយៗបានចំនួនពិតប្រាកដនោះទេ ដូច្នេះហើយក្នុងការគណនានេះគឺយើងរកចំនួនប្រហែលនៃដង់ស៊ីតេសត្វព្រៃដោយគិតជាក្រុមផងដែរ ។ នៅពេលដែលយើងប្រមូលបានទិន្នន័យគ្រប់គ្រាន់ការគណនាដង់ស៊ីតេ និងរបាយនៃប្រភេទសត្វព្រៃនីមួយៗ គឺយើងប្រើប្រាស់រូបមន្ត Distance Version 6.0 software (Thomas *et al*. 2009) ។






ទីតាំងសិក្សា និង បន្ទាត់ត្រង់សិក (ក្នុងព្រៃការពារ និង មួយចំនួនក្នុងព្រៃសម្បទានចិន្តាប្លាយវូត)

**តារាងទី១ : ទិន្នន័យត្រង់សិក**

| ឆ្នាំ | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | ចំនួនបន្ទាត់ត្រង់សិក | ប្រវែងសរុបត្រង់សិកជា គ.ម |
|---|---|---|---|---|
| ២០០៦ | ៤ ឧសភា | ២៣ មិថុនា | ២៧ | ១០៦.៤ |
| ២០០៧ | ២១ មេសា | ២៣ មិថុនា | ២៤ | ២៥២.៤ |
| ២០០៨ | ២៣ មេសា | ១៧ មិថុនា | ២៧ | ៤២១.៦ |
| ២០០៩ | ១៣ កុម្ភៈ | ១៣ មេសា | ២៦ | ៤៧៤.៦ |

## លទ្ធផល

### លទ្ធផលនៃការរាប់ចំនួនសត្វព្រៃ

យើងមិនអាចកំណត់របាយ និងដង់ស៊ីតេសត្វព្រៃបានទាំងអស់ និងសុក្រឹត្យនោះទេ ហើយយើងនឹងបង្ហាញពីលទ្ធផលនៃការរាប់ចំនួនសត្វព្រៃ តាងដោយក្រាហ្វិកដែលបង្ហាញពីកម្រិតលំអៀងនៃរបាយសត្វព្រៃ។ ការរាប់ចំនួនសត្វព្រៃគឺក្នុងពេលនេះ គឺភាគតាមក្រុមនៃប្រភេទនីមួយៗ អាស្រ័យទៅតាមចម្ងាយនៃប្រវែងត្រង់សិកសរុបតាមឆ្នាំនីមួយៗ ។ ការរាប់ចំនួនសត្វព្រៃពុំមែនជាការបង្ហាញពីដង់ស៊ីតេ ឬ របាយសត្វព្រៃនោះទេប៉ុន្តែការរាប់ចំនួនសត្វព្រៃនេះក៏អាស្រ័យលើបទពិសោធន៍នៃអ្នកអង្កេតហើយធ្វើឲ្យមានការប្រែប្រួលកម្រិតរបាយផងដែរ ។




ក្រាហ្វិកបង្ហាញពីចំនួនពពួកតិណាសីធំៗរួមមាន រមាំង ប្រើស ទន្សោង ខ្ទីង ដែលបង្ហាញពីស្តង់ដាកម្រិតលំអៀង នៃប្រភេទតាមត្រង់សិកនីមួយៗ










*ក្រាហ្វិកបង្ហាញពីចំនួនពពួក មំសាសីសត្វរួមមាន ខ្លែចចក ខ្លែព្រៃ សំពោច កញ្ជើង ឆ្លក ឈ្លូស ប្រែង ខ្ទីង សំពោចតូច ស្កាធំ ដែលបង្ហាញពីស្តង់ដាកម្រិតលំអៀងនៃប្រភេទ តាមត្រង់សិកនីមួយៗ*

ការវាយតម្លៃប៉ាន់ប្រមាណពីដង់ស៊ីតេ និងរបាយសត្វព្រៃ ការវាយតម្លៃពីដង់ស៊ីតេសត្វព្រៃដែលត្រូវបានធ្វើដោយខ្សែក រួមមាន ឈ្លូស និងក្តាន់ញែងតូច និងតារាងដង់ស៊ីតេជាក្រុមនៃពពួកជ្រូកព្រៃ ទោចម្គុដ ស្វាព្រាម

**តារាង ២ក:** ចំនួនប៉ាន់ប្រមាណដង់ស៊ីតេ និងរបាយប្រភេទសត្វព្រៃប្រភេទនីមួយៗ ។ យើងមិនអាចគណនារកដង់ស៊ីតេ នៃប្រភេទនីមួយៗបានគ្រប់រយៈ ៤ ឆ្នាំនេះបានទេ ដោយហេតុថាទិន្នន័យប្រភេទមួយចំនួននៅមានកម្រិតទាបប៉ុន្តែយើងអាចគណនារកភាគរយភាពជាក់លាក់បាន រហូតដល់ 95% CI = 95% confidence interval និង ភាគរយជាក់លាក់នៃមេគុណ % CV = % coefficient of variation ។

| ប្រភេទ | ឆ្នាំ | ដង់ស៊ីតេប្រភេទនីមួយៗ /គ.ម² | ភាពជាក់លាក់ដង់ស៊ីតេប្រភេទនីមួយៗរហូតដល់ 95% CI /km² | | ភាគរយបម្រែបម្រួលនៃមេគុណសម្រាប់ប្រភេទនីមួយៗ % CV | បរិមាណប្រភេទនីមួយៗ | ភាពជាក់លាក់បរិមាណប្រភេទនីមួយៗរហូតដល់ 95% 95% CI | |
|---|---|---|---|---|---|---|---|---|
| | | | អតិបរមា | អប្បរមា | | | អតិបរមា | អប្បរមា |
| ឈ្លូស | 2006 | 2.51 | 1.22 | 5.15 | 36.57 | 3,517 | 1,713 | 7,218 |
| | 2007 | 2.57 | 1.67 | 3.96 | 21.69 | 3,606 | 2,341 | 5,554 |
| | 2008 | 3.24 | 2.13 | 4.92 | 20.98 | 4,534 | 2,982 | 6,893 |
| | 2009 | 4.48 | 3.31 | 6.06 | 15.25 | 6,270 | 4,631 | 8,489 |
| ក្តាន់ញែងតូច | 2008 | 0.98 | 0.41 | 2.34 | 44.51 | 1,380 | 581 | 3,277 |
| | 2009 | 1.95 | 0.86 | 4.39 | 41.53 | 2,728 | 1,209 | 6,153 |

តារាង ២ខ: លទ្ធផលប៉ាន់ប្រមាណដង់ស៊ីតេជាក្រុម និងរបាយជាក្រុម។ ដង់ស៊ីតេនៃប្រភេទសត្វព្រៃជាក្រុមដែលបានបង្ហាញក្នុងតារាងនេះមានប្រភេទខ្លះពុំបានបង្ហាញតាមឆ្នាំនីមួយៗដោយហេតុថាកំណត់ត្រាពុំគ្រប់គ្រានតែយើងអាចបង្ហាញពីភាគរយនៃភាពជាក់លាក់ និងភាគរយបម្រែបម្រួលនៃមេគុណ ។

| ប្រភេទ | ឆ្នាំ | ដង់ស៊ីតេជាក្រុមប្រភេទនីមួយៗ /km² | ភាពជាក់លាក់ដង់ស៊ីតេជាក្រុមប្រភេទនីមួយៗ រហូតដល់95%ដី /km² | | ភាគរយបំរែបំរួលនៃមេគុណសំរាប់ក្រុមប្រភេទនីមួយៗ %CV | បរិមាណជាក្រុមប្រភេទនីមួយៗ | ភាពជាក់លាក់បរិមាណជាក្រុមប្រភេទនីមួយៗ រហូតដល់ 95% | |
|---|---|---|---|---|---|---|---|---|
| | | | អតិបរមា | អប្បរមា | | | អតិបរមា | អប្បរមា |
| ជ្រូកព្រៃ | 2007 | 0.41 | 0.18 | 0.95 | 42.79 | 573 | 248 | 1,326 |
| | 2008 | 1.13 | 0.59 | 2.15 | 32.39 | 1,581 | 829 | 3,016 |
| | 2009 | 2.55 | 1.78 | 3.65 | 17.77 | 3,573 | 2,499 | 5,108 |
| ទោចម្កុដ | 2006 | 0.62 | 0.24 | 1.56 | 47.93 | 865 | 341 | 2,191 |
| | 2007 | 0.35 | 0.13 | 0.91 | 50.16 | 487 | 185 | 1,281 |
| | 2008 | 0.36 | 0.16 | 0.81 | 40.76 | 511 | 230 | 1,137 |
| | 2009 | 0.30 | 0.13 | 0.70 | 43.21 | 418 | 179 | 974 |
| ស្វាព្រាម | 2009 | 0.45 | 0.20 | 1.04 | 42.71 | 634 | 276 | 1,456 |
| ស្វាក្អាម | 2007 | 0.24 | 0.10 | 0.57 | 44.92 | 330 | 137 | 793 |
| | 2008 | 0.26 | 0.11 | 0.60 | 42.52 | 363 | 158 | 836 |
| | 2009 | 0.29 | 0.15 | 0.56 | 33.30 | 407 | 210 | 790 |






ក្រាហ្វិក ដង់ស៊ីតេប៉ាន់ស្មានចំនួនសត្វឈ្លូសពីឆ្នាំ ២០០៦-២០០៧ ដែលបង្ហាញពីភាគរយនៃភាពជាក់លាក់ និង ភាគរយបម្រែបម្រួលនៃមេគុណ






ក្រាហ្វិក ដង់ស៊ីតេក្រុមទោចម្កុដរយៈពេល៤ឆ្នាំ២០០៦-២០០៩ បន្ទាត់កម្រិតលំអៀងជាក់លាក់រហូតដល់ ៩៥% កម្រិតលំអៀង

ជាក់លាក់នេះមានទំហំ ធំនេះពុំមែនមានន័យថារប៉ាយទោចម្កុដថយចុះនោះទេ តាមការវិភាគបង្ហាញថារប៉ាយទោចម្កុដគឺនៅថេរ






*ក្រាហ្វិក ដង់ស៊ីតេប៉ាន់ស្មានចំនួនសត្វឈ្លូសពីឆ្នាំ ២០០៦-២០០៧ ដែលបង្ហាញពីភាគរយនៃភាពជាក់លាក់ និង ភាគរយបម្រែបម្រួលនៃមេគុណ*

## ការពិភាក្សា

របាយការណ៍នេះបង្ហាញពីលទ្ធផលស្រាវជ្រាវពពួកថនិកសត្វធំៗក្នុងព្រៃការពារព្រះវិហារ និងតំបន់មួយចំនួនជាប់ព្រៃការពារ ការរាប់ចំនួនសត្វព្រៃបានបង្ហាញនូវតួលេខប្រែប្រួលរបាយ ប្រភេទសត្វព្រៃមួយចំនួន។ បានគណនា រកនូវដង់ស៊ីតេលើប្រភេទសត្វព្រៃមួយចំនួន ដែលបានបង្ហាញក្នុងរបាយការណ៍ស្រាប់ ។ តួលេខរបស់ពពួកតិណាសីបួនប្រភេទត្រូវបានរាប់ដូចជា រមាំង ប្រើស ទន្សោង និង ខ្ទីងជាដើម ប៉ុន្តែប្រភេទទាំងបួននេះមិនទាន់អាចកំណត់ដង់ស៊ីតេបាននៅឡើយទេ គ្រាន់តែរាប់ជាតួលេខសរុបនៃប្រភេទទាំងបួននេះតែម្តង ។ លទ្ធផលទាំងនេះគឺមានសារសំខាន់ណាស់ដើម្បីឈានទៅធ្វើកម្មវិធីត្រួតពិនិត្យរបាយសត្វព្រៃប្រភេទធំៗក្នុងព្រៃការពារដែលអាចនឹងទទួលបាននូវលទ្ធផលល្អ ទៅលើប្រភេទសត្វព្រៃមួយចំនួន ហើយយើងសង្ឃឹមថាផែនការគ្រប់គ្រង និង សកម្មភាពអនុវត្តជាក់ស្តែងពិតជាអាចទប់ស្កាត់បាននូវការបរបាញ់ និងការរំខានសត្វព្រៃ។ គួរកត់សំគាល់ដែរថា ប្រភេទមួយចំនួនដូចជា ឈ្លូស ជ្រូកព្រៃ ក្ដាន់ញែង និងពពួកមំសាសីសត្វជាដើម ដែលអាចនឹងងាយរងនូវការគំរាមកំហែងតាមរយៈការដាក់អន្ទាក់ ការបរបាញ់ជាអាហារ។ ប៉ុន្តែប្រភេទទាំងនេះក៏អាចបន្តពូជកើនឡើងវិញបានដែរប្រសិនបើយើងធ្វើការគ្រប់គ្រងត្រួតពិនិត្យបានត្រឹមត្រូវ ។

ប្រភេទដែលការបន្តពូជយូរដូចជាពពួកគោសាទិស ប្រើស រមាំង ទោចមុជ អាចមានរបាយនៅថេរ ក៏ដូចគ្នាដែរសម្រាប់ពពួកតិណាសី យើងមិនអាចគណនាដង់ស៊ីតេបានដោយហេតុថាចំនួនត្រង់សិកនៅមិនទាន់គ្រប់គ្រាន់។ គួរឲ្យកត់សំគាល់ផងដែរ ទោចមុជ យើងបានបង្កើននូវចំនួនត្រង់សិកគឺបានបង្ហាញនូវភាពជាក់លាក់នៃដង់ស៊ីតេជាក្រុម បើទោះបីជាយើងពុំទាន់អាចគណនាដង់ស៊ីជាចំនួនពិតបាន។ ការគណនាដង់ស៊ីតេសម្រាប់ទោចមុជ គឺត្រូវបានធ្វើឡើងទូទាំងប្រភេទទីជម្រក ប៉ុន្តែយើងសង្កេតឃើញថា វត្តមានទោចមុជ គឺមាននៅតែតាមព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងតែប៉ុណ្ណោះ (Phoonjampa & Brockelman 2008 ) នេះគឺមានន័យថាដង់ស៊ីតេ ទោចមុជ បើគិតតែក្នុងព្រៃស្រោង និងពាក់កណ្ដាលស្រោងគឺខ្ពស់ជាងតួលេខដែលយើងបានគណនាពេលនេះ។ គួរកត់សំគាល់ផងដែរថា នៅឆ្នាំ ២០០៨ - ២០០៩ មានភ្លៀងធ្លាក់ច្រើន នៅរដូវប្រាំងដែលធ្វើឲ្យមានប្រភពទឹកច្រើនបង្កើនចំណីសម្រាប់ ពពួកតិណាសី ដែលអាចឲ្យប្រភេទមួយចំនួនមានការកើនឡើងផងដែរដូចជាជ្រូកព្រៃជាដើម ។ ក្រុមអនុវត្តច្បាប់ ក្នុងព្រៃការពារគឺចាប់ផ្តើមដំណើរការល្អក្នុងឆ្នាំ ២០០៥ ពពួកតិណាសីមួយចំនួនត្រូវការរយៈពេលវែង ដើម្បីធ្វើការបន្តពូជ ដូច្នេះយើងគិតថាប៉ុន្មានឆ្នាំទៅមុខទៀតរបាយពពួក តិណាសីនឹងកើនឡើង។